# សម្ភាសន៍ជាមួយឈ្មោះ ដួស វៀវ ភេទប្រុស អាយុ៦៨ឆ្នាំ

មុខងារសម័យខ្មែរក្រហមៈ ប្រធានថ្នាំខ្មែរ

មានស្រុកកំណើតនៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

សព្វថ្ងៃរស់នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

សម្ភាសន៍ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០១:១១:០៨

២៧ទំព័រ

ដានីៈ អ៊ំដឹបូនខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ តើអ៊ំឈ្មោះអីដែរ?

វៀវៈ ខ្ញុំឈ្មោះដួស វៀវ កើតនៅឆ្នាំ១៩៤១ ។

ដានីៈ សព្វថ្ងៃអ៊ំរស់នៅភូមិឃុំអីដែរ?

វៀវៈ ខ្ញុំសព្វថ្ងៃរស់នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

ដានីៈ អ៊ំមានស្រុកកំណើតនៅណាដែរ?

វៀវៈ ស្រុកកំណើតខ្ញុំនៅភូមិស្វាយនេះតែម្តង ។

ដានីៈ អ៊ំស្រីគាត់ឈ្មោះអីដែរ?

វៀវៈ អ៊ំស្រីឈ្មោះស៊ុយ សុផល ។

ដានីៈ គាត់អាយុប៉ុន្មានដែរ?

វៀវៈ អាយុ៩០ឆ្នាំ ។

ដានីៈ បើអ៊ំមកដល់ឥលូវនេះគឺ?

វៀវៈ ខ្ញុំ៦៨ហើយ ។

ដានីៈ អ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

វៀវៈ ខ្ញុំមានកូនចៅ៩នាក់ ។

ដានីៈ មានកូន៩នាក់ ហើយស្រីប៉ុន្មានប្រុសប៉ុន្មាន?

វៀវៈ ស្រី៤នាក់ ហើយប្រុសមានតែ១ទេ ។

ដានីៈ សព្វថ្ងៃអ៊ំប្រកបមុខរបររកស៊ីធ្វើអីដែរ?

វៀវៈ ខ្ញុំប្រកបមុខរបរធ្វើស្រែ ។

ដានីៈ ក្រៅពីធ្វើស្រែមានធ្វើអីទៀតទេ?

រឿវៈ អត់មានធ្វើអីទៀតទេ ។

ដានីៈ ចុះអ៊ំកាលពីក្មេងៗអ៊ំរៀនសូត្រដល់ណាដែរ?

រឿវៈ ខ្ញុំបានចូលសិក្សាសាលាបឋមសិក្សាថ្មពួក ថ្នាក់ទី៧ ។

ដានីៈ ចុះកាលហ្នឹងអ៊ំរៀនដល់ថ្នាក់ទី៧អ៊ំឈប់រៀន?

រឿវៈ បាទ! ខ្ញុំឈប់រៀន ។

ដានីៈ មូលហេតុអីបានជាឈប់?

រឿវៈ មូលហេតុដែលឈប់ដោយសារខ្ញុំអត់មានបងប្អូនជួយបម្រើឪពុកម្ដាយ ។

ដានីៈ អញ្ចឹងអ៊ំមានបងប្អូនបង្កើតប៉ុន្មាននាក់?

រឿវៈ សព្វថ្ងៃនៅសល់បងប្អូនបង្កើតតែ៣នាក់ទេ ។

ដានីៈ អញ្ចឹងបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

រឿវៈ បងប្អូនបង្កើតទាំងអស់ ទាំងរស់ទាំងស្លាប់មាន៨នាក់ ។

ដានីៈ ៨នាក់ហ្នឹងស្រីប៉ុន្មានប្រុសប៉ុន្មាន?

រឿវៈ ស្រី១ ប្រុស៣នាក់ ។

ដានីៈ អ៊ំកូនទីប៉ុន្មាន?

រឿវៈ ខ្ញុំកូនទី១ ។

ដានីៈ បងគេបង្អស់?

រឿវៈ បាទ!

ដានីៈ ចុះឪពុកម្ដាយអ៊ំគាត់ឈ្មោះអីទៅ?

រឿវៈ ឪពុកខ្ញុំឈ្មោះសុខ ដួស ។

ដានីៈ ចុះម្ដាយ?

រឿវៈ ម្ដាយឈ្មោះព្រឹម សឿន ។

ដានីៈ សព្វថ្ងៃគាត់នៅរស់ឬក៏ស្លាប់ហើយ?

រឿវៈ គាត់ទទួលមរណៈភាពហើយ ។

ដានីៈ គាត់ស្លាប់តាំងពីអង្កាល់?

រឿវៈ គាត់ស្លាប់តាំងពីឆ្នាំ១៩៦៧ ។

ដានីៈ តាំងពីមុនសម័យ.... ។

រឿវៈ  បាទ! តាំងពីមុនសម័យយើងនេះណោះ ។

ដានីៈ  ហ្នឹងម្ដាយឬក៏ឪពុក?

រឿវៈ  ទាំងម្ដាយទាំងឪពុក ។

ដានីៈ  ទាំងពីនាក់តែម្ដង?

រឿវៈ  បាទ!

ដានីៈ  គាត់ស្លាប់ដោយសារអី?

រឿវៈ  គាត់ស្លាប់ដោយសាររោគគាពាធ ។

ដានីៈ  អញ្ចឹងអ៊ំឈប់រៀនមកជួយការងារឪពុកម្ដាយហ្នឹងនៅឆ្នាំណា?

រឿវៈ  ឆ្នាំ១៩៦២ ។

ដានីៈ  ឆ្នាំ៦២ អញ្ចឹងយូហើយ?

រឿវៈ  បាទ! យូហើយ ។

ដានីៈ  មកជួយធ្វើការងារយ៉ាងម៉េចខ្លះទៅ?

រឿវៈ  ធ្វើការងារដូចជា វាគ្មានអីនៅស្រុកស្រែយើងដូចថាចងគោ ឃ្វាលគោ ហើយបុកបាយជ្រូក ហើយនឹងបម្រើការងារមាតាបិតាតាមដែលគាត់ត្រូវការ ។

ដានីៈ  អ៊ំធ្វើការហ្នឹងរហូតដល់ពេលណាទៅបានអ៊ំរៀបការ?

រឿវៈ  ខ្ញុំធ្វើការរហូតដល់ឆ្នាំ១៩៦៩ខ្ញុំបានប្រពន្ធ ។

ដានីៈ  បានប្រពន្ធអ៊ំហ្នឹង?

រឿវៈ  បាទ!

ដានីៈ  ប្រពន្ធអ៊ំអ្នកស្រុកណា?

រឿវៈ  ប្រពន្ធខ្ញុំនៅភូមិនេះឯង ។

ដានីៈ  កាលហ្នឹងប្រពន្ធអ៊ំអាយុប៉ុន្មាន?

រឿវៈ  កាលហ្នឹងអាយុត្រឹមប៉ុន្មានទេ ប្រហែលជា១៩ហ្នឹង ។

ដានីៈ  ក្មេងដែរ?

រឿវៈ  ក្មេង ។

ដានីៈ  ឥលូវអាយុ៥០ហើយ?

រឿវៈ  បាទ!

ដានីៈ  អញ្ចឹងបើសិនជាគាត់អាយុ៥០កាលពីឆ្នាំ៦៩គាត់អាយុ១០ឆ្នាំជាងហ្នឹង?

រៀវៈ  បាទ!  កាលហ្នឹងដូចជាអាយុ១៨ ។

ដានីៈ  អញ្ចឹងការតាំងពីអាយុ១៨ឆ្នាំ?

រៀវៈ  បាទ!  ការរួចហើយវាអត់មានដំណើរការអីទេ  អត់មានសកម្មភាពអីក្នុងខ្លួនប្រាណឡើយរហូតដល់សព្វថ្ងៃ ។

ដានីៈ  ដល់ពេលការហើយអ៊ំនៅជាមួយគ្រួសារឬក៏យ៉ាងម៉េច?

រៀវៈ  សព្វថ្ងៃហ្នឹង?

ដានីៈ  អត់ទេពេលការហើយកាលឆ្នាំ៦៩?

រៀវៈ  កាលនោះពេលការហើយមកនៅជាមួយម្ដាយ  ហើយប្រកបការងាររួមជាមួយម្ដាយ ។

ដានីៈ  ម្ដាយក្មេក?

រៀវៈ  ម្ដាយក្មេកផង  ម្ដាយបង្កើតផង  តែចេញពីម្ដាយក្មេកមកនៅជាមួយម្ដាយបង្កើត  ដល់ពេលនៅជាមួយម្ដាយបង្កើតបានប៉ុន្មានឆ្នាំក៏ខ្ញុំបែកមកនៅតែឯង ។

ដានីៈ  អញ្ចឹងម្ដាយអ៊ំគាត់ស្លាប់ឆ្នាំណា?

រៀវៈ  ខ្ញុំដឹងតែឆ្នាំ១៩៦៧ ។

ដានីៈ  គាត់ស្លាប់ឆ្នាំ៦៧  ហើយអ៊ំការឆ្នាំ៦៩  អញ្ចឹងគាត់ស្លាប់អស់ហើយ?

រៀវៈ  គាត់ស្លាប់អស់ហើយ ។

ដានីៈ  ចុះដល់ពេលការហើយអ៊ំធ្វើស្រែធ្វើចំការ?

រៀវៈ  ពេលការហើយខ្ញុំប្រកបការងារដូចដែលខ្ញុំបានជម្រាបខាងដើមអញ្ចឹង ។

ដានីៈ  ចុះអ៊ំមានដែលបានចូលបដិវត្តខាងខ្មែរក្រហមដែរទេកាលជំនាន់ហ្នឹង?

រៀវៈ  កាលនោះខ្ញុំអត់ទាន់ចូលទេ  ពីព្រោះគេអត់ទាន់បានរើសរកខ្ញុំទេ  កាលនោះខ្ញុំដើរជាន់ស្មៅ  កាលហ្នឹងគេរើសដូចថាស្មៅមិនរាបគេឲ្យដើរជាន់ស្មៅ  ឲ្យជាន់ស្មៅឲ្យរាបទាំងអស់ ។

ដានីៈ  ឲ្យដើរជាន់ស្មៅ?

រៀវៈ  បាទ  ឲ្យដើរជាន់ស្មៅឲ្យលិចក្នុងផុក ។

ដានីៈ  ប៉ុន្មាននាក់ទៅ?

រៀវៈ  គេគិតឲ្យ១២នាក់ ។

ដានីៈ  ១២នាក់ ។

រៀវៈ  ក្នុងនោះវាមានឧបសគ្គ  ដូចជាខ្លួយអីហ្នឹងវាខ្ទេចជើងយើង  ដល់ពេលអញ្ចឹងវាដួលស្មៅហើយជាន់ទៅវាក៏ខាំ  ឲ្យតែខាំហើយយើងវេទនាហើយ  ប៉ុន្តែឲ្យតែដល់ថ្នាក់នោះហើយខ្ញុំសូមនិយាយ

ឲ្យវែងឆ្ងាយបន្តិចចុះ មិនហ៊ានស្រែកមិនហ៊ានអីទេព្រោះខ្លាចគេយកទៅវ៉ៃចោល មិនបានទេតែគេយកទៅវ៉ៃចោលវេទនាហ្នឹង ។

ដានី: ឆ្នាំណាដែលគេចាប់ផ្ដើមឲ្យអ៊ំជាន់ស្មៅហ្នឹង?

រៀវៈ បើគិតទៅវាឆ្នាំ១៩៧៥ហ្នឹងរហូតមកដល់ឆ្នាំ១៩៧៦ វេទនាណាស់មិនហ៊ានតម្រើកហ្នឹងគេទេព្រោះគេអាផងដឹបផង អាផងត្បូងចប និយាយឲ្យចំទៅមិនហ៊ាននិយាយអីទេ សូម្បីតែស៊ីបាយក៏ស៊ីមិនពេញពោះដែរព្រោះអង្កកន្ទះកំប៉ុង ។

ដានី: ពេលបែកឆ្នាំ៧៩ហើយគេឲ្យជាន់ស្មៅជាន់អី?

រៀវៈ បាទ! គេឲ្យជាន់ស្មៅ ។

ដានី: ជាន់ស្មៅដើម្បីអី?

រៀវៈ ជាន់ស្មៅឲ្យរាបដើម្បីកុំឲ្យទៅជាន់ស្រូវ ។

ដានី: កាលហ្នឹងអ៊ំអត់ទាន់មានតួនាទីអីទេ?

រៀវៈ អត់ទាន់មានតួនាទីអីទេ គឺនៅប្រជាជនសុទ្ធសាទ ។

ដានី: ហើយនៅក្នុងភូមិហ្នឹងដដែល?

រៀវៈ បាទ!

ដានី: គេអត់មានជម្លៀសទៅណាទេ?

រៀវៈ ជម្លៀសទៅនោះ និយាយពីរឿងជម្លៀសបន្តិច ខ្ញុំសូមជម្រាបជូនផងដែរថាគេជម្លៀសខ្ញុំហើយនឹងអ្នកនៅក្នុងភូមិនេះប្រហែលជា២០គ្រួសារ ហើយខ្ញុំទៅគ្មានគោគ្មានក្របីហ្នឹងគេទេ ជិះរទេះទៅជាមួយគេ ហើយពេលគេទៅគេនិយាយខាងផ្នែកនយោបាយ គេថាបើនរណាផ្ទះស្បូវគេឲ្យនៅផ្ទះស័ង្កសី គ្រាន់តែពួកអញ្ចឹងគ្នាខំអរ ដល់ពេលខ្ញុំបាទទៅដល់ផុតស្វាយទៅដេកនៅស្ពាន ទៅដេកនៅស្ពានធ្លាក់កូនធ្លាក់ចៅ ហើយខ្ញុំចេះតែស៊ូទៅ ដល់បន្តិចទៅបានគេឲ្យមកគេថាអារ៉ាក់បាក់ក ដល់អារ៉ាក់បាក់កហើយមកដល់ខាងឈ្នូខាងលិចភ្នំជញ្ជាំង ស្គាល់ភូមិជញ្ជាំងទេ?

ដានី: ស្គាល់ ។

រៀវៈ ទីនោះឯងជាទីអាក្រក់បំផុតដូចជាមច្ចុរាជអញ្ចឹង ។

ដានី: ខាងស្រុកព្រះនេត្រព្រះមែនភ្នំជញ្ជាំង?

រៀវៈ នៅព្រះនេត្រព្រះ ហើយក៏ដើរឃ្វាលគោឃ្វាលម៉ាតាមសេចក្ដីត្រូវការរបស់គេដែលគេចង់ប្រើខ្ញុំបាទនេះឯង ហើយខ្ញុំមិនដឹងធ្វើម៉េចមិនដឹងត្រូវគេចខ្លួនទៅណាព្រោះគេនៅគៀបសងខាង ដូច្នេះខ្ញុំសូមស្នេះត្រឹមហ្នឹងឲ្យគេជគុណាសួមកខ្ញុំទៀតចុះ ។

ដានី៖ ម៉េចបានជាគេជម្លៀសអ៊ីប៉ុន្មានគ្រួសារហ្នឹងទៅ?

វៀវ៖ ដែលគេជម្លៀសនេះព្រោះគេតម្រូវឲ្យយើងទៅនៅស្វាយ អ្នកណាផ្ទះស្បូវឲ្យទៅនៅផ្ទះស័ង្កសី ផ្ទះថ្ម ការពិតអត់ទេឲ្យយើងទៅដេកដីសោះ អាហ្នឹងជាក់ស្តែងតែម្តង ។

ដានី៖ ដោយសារមានទិន្នាការអីបានជាគេជម្លៀសអ៊ំទៅ?

វៀវ៖ ខ្ញុំអត់មានទិន្នាការអីទេ តែខ្លះគេធ្វើប្រធានលន់ នល់ ខ្លះគេធ្វើស្វាយគ្រាន ហើយខ្ញុំនេះបានធ្វើស្វាយគ្រានទឹងគេបន្តិចដែរ ។

ដានី៖ ដល់អញ្ចឹងគេជម្លៀសអ៊ំទៅ?

វៀវ៖ បាទ! គេជម្លៀសខ្ញុំទៅ ។

ដានី៖ ទៅដល់ភ្នំជញ្ជាំងហ្នឹង?

វៀវ៖ ទៅដល់ស្វាយហើយទៅដេកនៅខាងកើតស្វាយ ។

ដានី៖ ទៅដេករយៈពេលប៉ុន្មាន?

វៀវ៖ ទៅដេកមួយយប់ ដេកមួយយប់ហើយបានក្រោកទៅទៀតទៅដល់ភ្នំជញ្ជាំង ដល់ពេលទៅដល់ភ្នំជញ្ជាំងរកកន្លែងមិនបានដេក បានកូនស្បូវប្រហែលជាពីបីបន្ទុះបានក្រាលឲ្យកូនចៅដេក ដេករួចហើយក៏ភ្លៀងទៀតវេទនាណាស់ស្ទើរតែនិយាយមិនរួច ដូច្នេះខ្ញុំបានបាទមានការលំបាកវេទនានៅសម័យប៉ុល ពតនោះដូចថាសុខភាពអីវ៉ាបែកខ្ទេចខ្ទីអស់ ។

ដានី៖ ហើយកាលគេឲ្យដាន់ស្មៅហ្នឹងដាន់នៅខាងនោះ?

វៀវ៖ ដាន់នៅវាលស្រែនេះ ។

ដានី៖ អញ្ចឹងឆ្នាំណាដែលគេជម្លៀសទៅហ្នឹង?

វៀវ៖ ឆ្នាំប៉ុន្មានទេខ្ញុំភ្លេចបាត់ហើយ កាលហ្នឹងដូចជាឆ្នាំ៧៥ ។

ដានី៖ កាលគេជម្លៀសទៅហ្នឹងឆ្នាំ៧៥ ?

វៀវ៖ បាទ!

ដានី៖ ចុះកាលដាន់ស្មៅហ្នឹងដាន់តាំងពីឆ្នាំណា?

វៀវ៖ ស្មៅហ្នឹងដាន់តាំងពីឆ្នាំចូល ខ្ញុំភ្លេចអស់មិនបានគិតគូទេ តាំងពីឆ្នាំចូលម្លេះ ។

ដានី៖ ចូលយ៉ាងម៉េច?

វៀវ៖ តាំងពីគេចូលមក គេលើកទង់សមកហើយគេរៀបចំឲ្យដាន់ស្មៅ ។

ដានី៖ ដល់ពេលណាទៅបានគេចាត់អ៊ំឲ្យធ្វើប្រធានការសេដ្ឋកិច្ចគេហ្នឹង?

វៀវ៖ កាលធ្វើប្រធានសេដ្ឋកិច្ចនោះពេលដែលខ្ញុំមកពីនោះ ។

ដានី៖ មកពីណា?

វៀវ៖ ពេលដែលខ្ញុំត្រលប់មកពីភ្នំដញ្ញាំងវិញ ត្រលប់មកពីភ្នំដញ្ញាំងវេទនាណាស់ គេតាមហើយងាប់គ្នាខ្ញុំអស់៣នាក់ គេចាប់យកទៅដាក់នៅថ្មពូកហើយសម្លាប់ចោល ហើយគេទុកខ្ញុំក្រោយ ដល់ពេលគេទុកខ្ញុំក្រោយទៅហើយគេមកសួបងខ្ញុំនៅផ្ទះខាងត្បូង ម៉េចៗគេប្រាប់ថាឥលូវមិនអីទេអានេះនោះ អាមិត្តនេះវាធ្វើការចំណាប់គេផ្អកហើយទៅវិញ ហើយគេមកសួទៀត ដល់ពេលគេមកសួទៀតហើយគេក៏ឈប់ ដល់ហើយយោធាគេមកមួយក្រុមធំទៀតមកសួទៀត ក្រុមយោធាហ្នឹងសួតែដដែលៗដល់វានិយាយឲ្យចំដល់វាប្រាកដទៅបានវាឈប់ហើយវាឈប់មកសួដេញដោល ដល់ពេលគេឈប់សួទៅខ្ញុំនេះក៏បានបង្កើតជាឈ្លប ខ្ញុំមិនដឹងថាគេយកទៅដាក់នៅក្នុងជម្រុកនោះចំនួនមួយអាទិត្យ។

ដានី៖ ដាក់ណា?

វៀវ៖ ដាក់ជម្រុកថ្មពូក សង្កាត់ថ្មពូក ពេលដាក់នៅក្នុងថ្មពូកនោះគេសួៗសព្វគ្រប់ សួថាធ្វើអីខ្លះៗសព្វគ្រប់ណាំរួចហើយបានគេលែង ដល់ពេលគេលែងហើយបានគេបញ្ជូនខ្ញុំឲ្យមកភូមិវិញ ដល់ពេលមកនៅភូមិវិញបានគេឲ្យធ្វើប្រធានក្រុម អាហ្នឹងនិយាយការពិតតែម្ដង ឲ្យធ្វើប្រធានក្រុមនៅក្រុមទី១០ ដល់ពេលនៅក្រុមទី១០រួចហើយគេបញ្ជូនខ្ញុំឲ្យទៅនៅក្រុមទី១១នៅជិតត្រពាំងស្វាយ ដូច្នេះខ្ញុំទៅត្រពាំងស្វាយរួចហើយបានគេបញ្ជូនខ្ញុំឲ្យទៅនៅត្រពាំងព្រីង ទៅនៅសួងស្រែនៅទីនោះ ហើយទៀតក៏ខ្ញុំនៅខែនោះមានឈ្មោះតា ជៀបមួយគាត់ធ្វើប្រធានសហករណ៍គេគាត់ចាប់យកទៅវ៉ៃគេវ៉ៃទៅគាត់ទៅនៅក្រោមគេ វ៉ៃមិនងាប់វ៉ៃមិនត្រូវវានៅក្រោមគេ ដល់ពេលប៉ុល ពតវាមកអស់បានតាជៀបហ្នឹងគាត់ចេញមក គេចមកគាត់មកប្រាប់ខ្ញុំថានែ៎ទៅប្រាប់មិត្តវៀវផងមិនរស់ទេពួកឯងបើសិនជាពួកឯងមិនរត់ បើមិនរត់ត្រូវតែស្លាប់ ខ្ញុំមានកូនស្រីម្នាក់មកប្រាប់ខ្ញុំថា លោកបងតាជៀបឲ្យទៅជួបគាត់នៅកោះ ដល់ពេលទៅដល់រកគាត់ហើយគាត់ថាឯងរៀបចំខ្លួន ហើយខ្ញុំក៏សួគាត់ថាម៉េចអញ្ចឹង ហើយគាត់ឆ្លើយថាឯងមើលអញគេវ៉ៃជិតងាប់ហើយនៅក្រោមគេទៅបានអញរស់ ដល់ពេលនេះទៅខ្ញុំទៅជួបគាត់ គាត់ថាឯងត្រូវតែរៀបចំ ហើយខ្ញុំថារៀបចំយ៉ាងម៉េច ហើយគាត់ថាមិត្តត្រូវរៀបចំហើយរត់គេចចេញទៅគ្មានអ្នកណារស់មួយទេឥលូវនេះ ហើយខ្ញុំក៏ដើរបបួលគេដើម្បីរត់ ហើយអ្នកខ្លះគេថាគេមិនរត់ទេអ្នកណារត់យកប្រពន្ធទៅឲ្យអស់ទៅ ហើយដល់ពេលនោះទៅខ្ញុំក៏ដើរបបួលគ្នា ដល់ពេលដើរបបួលគ្នាអញ្ចឹងគេសួថាទៅណាហើយខ្ញុំថាដើររកក្របីតាមពិតដើរបបួលគ្នារត់ ព្រោះបើវាមិនផុត ព្រោះខ្ញុំមិនដឹងរកពាក្យដោះស្រាយយ៉ាងម៉េច ហើយដល់ពេលនេះទៅខ្ញុំបបួលគ្នាបាន

១៨នាក់ ១៨នាក់ខ្ញុំយកអង្ករប៉ុណ្ណេះ ហើយសាច់ជ្រូកប៉ុណ្ណេះ បើអាយ៉ាននោះស៊ីអង្ករឆៅ ហើយស៊ីសាច់ឆៅព្រោះវាហេវវា ហើយពេលទៅដល់ជាយដែនទៅប៉ះខ្មែរសគេនាំគ្នារត់ រត់ពីនេះទៅណា៎ ដល់ពេលទៅដល់ហើយខ្មែរសគេចាប់ពួកខ្ញុំនេះទៀត កាលនោះគេសួរកថាអ្នកណាធ្វើប្រធានអីខ្លះ អ្នកណាធ្វើប្រធានកង អ្នកណាធ្វើប្រធានក្រុម អ្នកណាធ្វើសេដ្ឋកិច្ច អ្នកណាធ្វើអីខ្លះហើយក៏ប្រាប់គេតាមនោះទៅគេក៏ចាប់ពួកខ្ញុំទុកមួយឡែកគ្នា៧នាក់ ហើយគេក៏អាមេកាំភ្លើងកាំប៉េចកាំប៉ុកអាហ្នឹងពួកខ្មែរសណា៎ ។

ដានី: បាទ!

វៀរៈ និយាយទៅចង់តែសើចព្រោះវាវេទនាពេក ដូច្នេះហើយរត់ជាមួយអានេះ ជាមួយអាខ្មៅនេះឯង ដល់ហើយទៅក៏គេឲ្យអាពួកប៉ុន្មានរយនាក់នោះឡើងឡានអស់ ហើយគេទុកខ្ញុំតែ៧នាក់ទេ ហើយក៏គេបញ្ជូនទៅវិញ បញ្ជូនទៅវិញទៅនៅកន្លែងដដែល ទៅនៅកន្លែងដដែលនៅកន្លែងព្រៃនោះ ដល់ពេលទៅដល់កន្លែងព្រៃអ្នកដែលស្គាល់យើងគេមិននិយាយជាមួយយើងទេព្រោះវាខ្លាំងអញ្ចឹងវាមិននិយាយជាមួយយើងទេ ដល់នេះទៅបានគេចងមួក ដល់ពេលគេចងមួកទៅគេថាបើអ្នកណាឃ្លានដក់បារីដក់ទៅ បើអ្នកណាមិនឃ្លានទេកុំដក់ បើអ្នកណាដក់ៗឲ្យហើយទៅ គេចងមួកអស់ ហើយខ្ញុំកាន់សាសនាដូចថាមានតែព្រះពុទ្ធព្រះធម៌ព្រះសង្ឃជួយខ្ញុំព្រះករុណាខ្ញុំបាទផងព្រោះខ្ញុំបាទមានទោសហើយ មានអាសន្នហើយនៅសម័យប៉ុល ពតនេះកំពុងតែសាររៀរកអាយុសង្ខារមនុស្សច្រើនណាស់ ជួយខ្ញុំបាទព្រះករុណាផងលើកដៃទៅលើហើយបួងសួង អង្គុយអញ្ចេះ ហើយគេយាមនៅខាងនោះមួយ យាមខាងនេះមួយ ហើយគេអាមេកាំភ្លើងប្រាវៗ ដល់ពេលគេមកដល់គេអង្គុយនៅឲ្យស្ងៀមអាហ្នឹងពួកខ្មែរសទេណា៎ ។

ដានី: បាទ!

វៀរៈ អាហ្នឹងដល់ខ្មែរសហើយ ហើយគេថាអង្គុយនៅឲ្យស្ងៀមបើអ្នកណាឃ្លានដក់ៗទៅ ហើយបើអ្នកណាភាវនាក៏ភាវនាទៅ គេធ្វើហ្នឹងធ្វើខ្លាំងណាស់ ហើយមានអីខ្ញុំដក់មិនរួចហ្នឹងគេទេវេទនាណាស់ ប៉ុន្តែខ្ញុំអត់មានស្រក់ទឹកភ្នែកនឹងគេទេ គិតក្នុងចិត្តថាអញគឺជាមនុស្សអញគឺត្រូវមានកម្មអញដល់ពេលវេលាហើយអញត្រូវតែតស៊ូ ស្លាប់ក៏មិនអីរស់ក៏មិនអី ដាច់ចិត្តអញ្ចឹងតែម្តង ខ្ញុំបាទសូមជម្រាបតាមការពិតដែលបានឃើញជាក់ស្តែង ដែលបានអនុវត្តជាក់ស្តែងនៅក្នុងបញ្ហាសម័យប៉ុល ពត ខ្ញុំសូមត្រឹមនេះចុះទុកឲ្យអូនសួម្តង ។

ដានី: ចុះអ៊ំបន្ទាប់ពីជម្លៀសពីភ្នំជញ្ជាំង ទៅភ្នំជញ្ជាំងហើយអ៊ំត្រលប់ទៅវិញ?

វៀរៈ បាទ!

ដានីៈ ឆ្នាំណាត្រលប់មកវិញហ្នឹង?

វៀវៈ ឆ្នាំ៧៧ ។

ដានីៈ អញ្ចឹងឆ្នាំ៧៧ត្រលប់មកវិញ?

វៀវៈ បាទ!

ដានីៈ កាលទៅនៅភ្នំដញ្ញាំងគេឲ្យធ្វើអីខ្លះ?

វៀវៈ កាលនៅភ្នំដញ្ញាំងគេឲ្យគាស់ចំការដាំកប្បាស មួយគីឡូម្តង បានមួយគីឡូមែន ខ្ញុំគាស់ចំការបាន មួយគីឡូដាំរួចរាល់អស់ហើយ ។

ដានីៈ មួយគីឡូបួនជ្រុង?

វៀវៈ បាទ! ខ្ញុំសូមជម្រាបតទៅទៀត ដល់ពេលនេះខ្ញុំទៅហើយខ្ញុំថា លោកប្រធានឈ្លបធំគេថាមិត្ត ដូស វៀវ មិត្តមិនបាច់ទៅចំការទេ ឲ្យនៅមើលអ្នកជម្ងឺ មើលអ្នកឈឺ ហើយខ្ញុំមើលមួយ សហករណ៍ហ្នឹងហ្នង មើលបានជាល្អទាំងអស់អត់មានការខូចខាតអ្វីទេ ដល់បន្ទាប់មកទៀតចេះ តែដើររកថ្នាំរកអីទុកឲ្យកូនក្មេងកូនង៉ាដឹក ប៉ុន្តែស្តោះគ្រោះមិនឲ្យទេណា៎ ប៉ុន្តែដោយសារមិនគ្រប់ ខ្ញុំស្ងោរទុកទាំងដបៗ ។

ដានីៈ គ្រូបុរាណ?

វៀវៈ បាទ! គ្រូតាំងពីសម័យរាជានិយម សម័យសម្តេចឪ ។

ដានីៈ ថ្នាំអីខ្លះទៅគ្រូបុរាណហ្នឹង?

វៀវៈ ថ្នាំមានថ្នាំអីមានតែពួកថ្នាំតាន ។

ដានីៈ ថ្នាំតានហ្នឹងយ៉ាងម៉េច?

វៀវៈ ថ្នាំតានហ្នឹងដូចថាវាស៊ីមាត់ ស៊ីអណ្តាតស៊ីអីហ្នឹងហើយយើងដឹកទៅវាជា រាគរូសអីហ្នឹងក៏តាន ដែរ ហើយមានគ្រុនចាញ់ គ្រុនផ្តាសាយ ហើយមានចាស់ខ្លះគាត់ឈឺចុកពោះចុកអីដូចដាក់ទៅ វាជាហើយសមប្រកបវាអត់មានគ្រោះថ្នាក់អីអាហ្នឹងខ្ញុំនិយាយតាមការពិតតែម្តង ។

ដានីៈ ចុះមើលច្រើនដែរកាលហ្នឹង?

វៀវៈ មើលច្រើន ។

ដានីៈ អាហ្នឹងគេចាត់ឲ្យអ៊ំធ្វើ?

វៀវៈ សហករណ៍គេចាត់ឲ្យខ្ញុំធ្វើ បើគេមិនចាត់ឲ្យយើងធ្វើហើយយើងធ្វើតាមតែចិត្តឯងមុខជាខ្ទង់ចប ហើយ ធ្វើអ្វីសុទ្ធតែមានខទ្មេសនាមគេ បើគេឲ្យធ្វើគឺត្រូវតែធ្វើ បើគេមិនឲ្យធ្វើទេគឺធ្វើមិនបាន ដាច់ខាត អាហ្នឹងតាមខទ្មេសនាមរបស់គេ ដែលគេហៅថាបញ្ជានោះ ។

ដានី៖ ថ្នាំហ្នឹងអ៊ំដើររកក្នុងព្រៃខ្លួនឯងឬក៏ម៉េច?

វៀវ៖ បាទ! រកមកស្លខ្លួនឯង ស្លដាក់ដប ហើយអ្នកណាឈឺអីដាក់ទៅបាត់តែម្តង រាគគ្រុនអីព្រោះថ្នាំវាមានមុខច្រើន បាយរញ៉េរញ៉ៃ រដេញមាសអាហ្នឹងយើងចេះតែដាក់ទៅណា ដាក់ថ្នាំពិសេសៗល្អៗហើយមានដើមកន្ទ្រាំងស្អីៗសព្វមុខខ្ញុំមិនបានរៀបរាប់អស់ទេព្រោះថ្នាំច្រើនណាស់ កូនចៅណារាគអីដាក់ទៅជាតែម្តង ។

ដានី៖ ចុះដែលនៅនោះកាលនោះគេហៅកន្លែងអីគេ?

វៀវ៖ កន្លែងនោះគេហៅភ្នំជញ្ជាំង ។

ដានី៖ ដែលគេហៅសហករណ៍ស្អីគេទេ?

វៀវ៖ បើយើងទៅអញ្ចេះគេហៅថ្មពួក គេដាក់ឈ្មោះសហករណ៍ថ្មពួក ។

ដានី៖ ហើយចុះភ្នំជញ្ជាំងគេហៅសហករណ៍អីគេ?

វៀវ៖ ភ្នំជញ្ជាំងភូមិគោកលន់គេ ។

ដានី៖ ភូមិគោកលន់?

វៀវ៖ បាទ!

ដានី៖ ឃុំអីអាហ្នឹង?

វៀវ៖ ឃុំព្រះនេត្រព្រះ ។

ដានី៖ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ?

វៀវ៖ បាទ!

ដានី៖ អ៊ំធ្វើពេទ្យនៅហ្នឹងបានយូទេ?

វៀវ៖ ខ្ញុំអត់មានបានធ្វើពេទ្យទេ ដូចខ្ញុំបាទបានជម្រាបជូនអញ្ចឹងថាគេដាក់ឲ្យធ្វើខាងគ្រូខ្មែរសង្គមកិច្ច ។

ដានី៖ គ្រូខ្មែរសង្គមកិច្ច?

វៀវ៖ បាទ! គ្រូខ្មែរសង្គមកិច្ចថ្នាំធម្មជាតិយើង ។

ដានី៖ ធ្វើគ្រូខ្មែរសង្គមកិច្ចយើងមិនបាច់ទៅធ្វើស្រែធ្វើចំការអីទេ?

វៀវ៖ កាលពីមិនទាន់ដាំកប្បាស់ដាំផ្ការួចទៅ ដល់ពេលរួចហើយគេឲ្យយើងឈប់ គេឲ្យឈប់នៅថែរក្សាបងប្អូន ។

ដានី៖ គេឲ្យនៅថែរក្សាបងប្អូន ។

វៀវ៖ បាទ! ឈប់យប់ ហើយដេកស្រួលយ៉ាងណាក៏ដោយក៏ត្រូវតែមើលគេ បើមិនមើលគេទេគឺត្រូវមានទារុណកម្មយ៉ាងធ្ងន់ធ្ងរជាទីបំផុត ។

ដានី៖ ម៉េចបានដឹង?

វៀវ៖ មិនធម្មតាទេ ព្រោះឈ្លបវាច្រើន ។

ដានី៖ ប៉ុន្តែអ៊ំធ្លាប់អត់ទៅមើលគេ គេធ្វើទារុណកម្មដែរ?

វៀវ៖ ខ្ញុំមិនដែលបានធ្វើទារុណកម្មទេព្រោះខ្ញុំវាងាសដែរ ឲ្យតែមានអ្នកណាឈឺខ្ញុំប្រុច ចុកពោះចុកអី ប្រុចព្រោះថ្នាំខ្ញុំមានស្រេច អត់មានច្រើនទេ មានតែស្រាដូខៀវ និងសំបកស្រែងបើដឹកទៅក្អួតមកហើយបាត់ វាច្រើនតែរស់ដោយសារអានោះឯងកាលសម័យនោះ ។

ដានី៖ អញ្ចឹងធ្វើគ្រូខ្មែរបានរយៈពេលប៉ុន្មាន?

វៀវ៖ បានមួយរយៈពេលរួចរដូវកប្បាស ។

ដានី៖ រួចរដូវកប្បាស?

វៀវ៖ បាទ!

ដានី៖ ហើយគេផ្លាស់មកវិញ?

វៀវ៖ ថាផ្លាស់ក៏មិនមែនផ្លាស់ដែរ វាអញ្ចេះវាមើលទៅវាអត់មានអីទីពឹងផង ប្រជុំយនាំគ្នាបរទេសមក

ដានី៖ បរទេសមកហើយឈ្លបគេអត់មានថាអីទេ?

វៀវ៖ ឈ្លបគេមិនថាអីទេ គេឲ្យមក ។

ដានី៖ គេឲ្យមកដែរ?

វៀវ៖ បាទ! មកដាំបាយស៊ីនៅកន្លែងទម្លាប់ នាំគ្នាបាចត្រីបាចអីស៊ី ជាមួយបងប្អូនស្លេកស្លក់ចេះតែនាំគ្នារកអីស៊ីទៅ កាលពីមុនអត់មានអីទទួលទានទេ សូម្បីតែអំបិលយើងក៏យ៉ាប់ដែរ ហើយអង្ករក៏អត់មានរកបានដែរ បានតែមួយកំប៉ុងចែកគ្នាបបរស៊ីតែបានមកដល់ផ្ទះ ដល់ពេលមកដល់ផ្ទះគេមិនទទួលទៀត ពេលខ្លះបានអង្ករកន្លះកំប៉ុងអញ្ចឹងទៅហើយនាំគ្នាបបរចែកគ្នាស៊ីអញ្ចឹងទៅគ្នា១០ជាងអង្ករកន្លះកំប៉ុង បើយើងមិនតស៊ូមិនមែនបានរស់មកដល់សព្វថ្ងៃនេះទេ បើនិយាយទៅវាវេទនាណាស់សូម្បីតែខោអាវក៏អត់មានពាក់ ។

ដានី៖ អញ្ចឹងឆ្នាំ៧៨អ៊ំត្រលប់មកដល់ហ្នឹងវិញ?

វៀវ៖ បាទ!

ដានី៖ អញ្ចឹងពេលហ្នឹងគេអត់មានថាអីទេ យើងអាចមកដោយចិត្តឯងណោះ?

វៀវ៖ ថាដែរតែថាវាទៅមិនរួច គេអត់មានថាអីច្រើនទេ គ្រាន់តែថាមួយម៉ាត់ពីម៉ាត់ចប់បាត់ទៅហើយរួចគ្នាហើយ ។

ដានី៖ ប៉ុន្តែដូចថាយើងជម្លៀសមកផ្ទះវិញអញ្ចឹងគេអត់មានថាអីទេ?

រឿវៈ	អាហ្នឹងកាលមកពីភ្នំពេញ្ញរាំង?

ដានីៈ	បាទ!

រឿវៈ	អាហ្នឹងពួកខ្ញុំរត់មកតើ ។

ដានីៈ	អ៊ំរត់មកទេ?

រឿវៈ	បាទ!

ដានីៈ	ចុះគេអត់មានតាមទេ?

រឿវៈ	អត់មានតាមទេ ។

ដានីៈ	ម៉េចបានរត់មក?

រឿវៈ	ព្រោះកប្បាសវាផ្លែហើយ ហើយវាទុំទៀត ហើយមានគេអ្នកបេះផ្សេងអញ្ចឹងយើងអស់ការកិច្ច ហើយយើងមក ហើយគេមិនឲ្យយើងមកដោយសារតែយើងមានចិត្តកំណាចដាច់ខាតថាផាប់ចោលរស់ក៏យកទៅ ហើយក៏នាំគ្នាមក ។

ដានីៈ	មកទាំងអស់គ្នា ទាំងគ្រួសារទាំងអីទាំងអស់?

រឿវៈ	បាទ! ដល់ពេលមកដល់ផ្ទះនេះបានធ្វើទុកខ្លាំង មកដល់ភូមិនេះបានធ្វើទុកខ្លាំង ។

ដានីៈ	ធ្វើទុកម៉េចទៅ?

រឿវៈ	ចាប់៣នាក់យកទៅសម្លាប់ចោល ។

ដានីៈ	ម៉េចបានជាគេចាប់៣នាក់យកទៅសម្លាប់ចោល?

រឿវៈ	អានោះប្រវត្តិគេនោះគឺប្រធានភូមិ សុទ្ធតែពួកប្រធានភូមិចាស់ ហើយខ្ញុំនេះមិនបានធ្វើអីនឹងគេទេ បានធ្វើតែស៊ាយគ្រានមួយខែប៉ុណ្ណោះឯង អត់មានបានដាប់អីនឹងគេទេ ។

ដានីៈ	ចុះធ្វើសេដ្ឋកិច្ចម៉េចដែរ?

រឿវៈ	សេដ្ឋកិច្ចនេះធ្វើ...?

ដានីៈ	ពីជំនាន់ណា?

រឿវៈ	សេដ្ឋកិច្ចនេះធ្វើកាលជំនាន់ប៉ុល ពតនេះឯង ដែលគេឲ្យធ្វើនោះ ។

ដានីៈ	ធ្វើពីឆ្នាំណាមក?

រឿវៈ	ខ្ញុំមិនបានគិតគូរឿងឆ្នាំទេ ។

ដានីៈ	ពេលត្រលប់មកពីភ្នំពេញ្ញរាំងវិញបានធ្វើប្តូក៏ធ្វើមុនហ្នឹង?

រឿវៈ	ធ្វើពេលត្រលប់មកពីភ្នំពេញ្ញរាំងវិញ អាហ្នឹងគេឲ្យធ្វើគេយកមកដាក់នៅថ្នូពួកបាន៣យប់៣ថ្ងៃ កាលហ្នឹងគេវៃចោលហើយ តែគេអត់មានវៃចោលផង សន្កាត់គេទុក ។

ដានី៖ សន្តាត់ហ្នឹងឈ្មោះអី?

រៀវ៖ សន្តាត់គេឈ្មោះ សាុំ ។

ដានី៖ មកពីណាមក?

រៀវ៖ មកពីខាងក្រោមនោះ ។

ដានី៖ ខាងក្រោមហ្នឹងនៅណា?

រៀវ៖ មិនដឹងជាខាងកំពតអីមិនដឹងទេ ។

ដានី៖ គេហៅអីកាលជំនាន់ហ្នឹង?

រៀវ៖ មិនដឹងជាខាងកំពង់ចាមមិនដឹង មិនដឹងជាខាងនាវតីមិនដឹងព្រោះខ្ញុំមិនបានសាកសួរទេ មុខគេដូចថាសុទ្ធតែមុខដែលយើងមើលមិនសូវបានសោះ មើលទៅរាងតែខ្លាច ។

ដានី៖ អញ្ចឹងគេចាប់ទៅ៣នាក់ ហើយអ៊ំធ្លាប់ធ្វើការនៅស្វាយត្រាំ?

រៀវ៖ ខ្ញុំធ្វើការនៅស្វាយត្រាំបានរយៈពេលមួយខែ ។

ដានី៖ ស្វាយត្រាំរបស់លន់ នល់មែន?

រៀវ៖ ស្វាយត្រាំរបស់លន់ នល់ហ្នឹងខ្ញុំយាមទេនៅថ្មពួក ។

ដានី៖ គេចាប់អ៊ំទៅដែរ?

រៀវ៖ ហើយប៉ុល ពតគេកោះខ្ញុំយកទៅ ។

ដានី៖ បាទ! គេឃាត់ខ្លួនអ៊ំរយៈពេលប៉ុន្មានទៅ?

រៀវ៖ ប្រហែលជាមួយអាទិត្យ ។

ដានី៖ មួយអាទិត្យនៅវត្តថ្មពួកហ្នឹងមែន?

រៀវ៖ មិនមែននៅវត្តទេ គេឲ្យទៅនៅបន្ទាយគាសិន នៅហ្នឹងគេហៅបន្ទាយគាសិន បើដិះទៅឃើញហើយបន្ទាយហ្នឹង ។

ដានី៖ បន្ទាយគាសិន?

រៀវ៖ បាទ!

ដានី៖ ចុះ២នាក់ទៀតគេសម្លាប់ ហើយគេទុកតែអ៊ំមួយ?

រៀវ៖ ៣នាក់គេសម្លាប់ ។

ដានី៖ អញ្ចឹង៤នាក់ទាំងអ៊ំ?

រៀវ៖ ខ្ញុំគេមិនគិតទេចាប់ទេ គេកំពុងតែឆ្អែល កំពុងតែក្រឡឹងសួប្រវត្តិរូប ដល់ពេលសួទៅមិនដឹងប្រវត្តិរូបយ៉ាងណាបានត្រូវសល់ មិនដែលក្រឡេចក្រឡុចទេតស៊ូចង់ដឹងមើល ។

ដានី៖ ដល់ហើយបន្ទាយសន្តាត់ប្រលែងអីវិញ?

រៀវ៖ គាត់ប្រលែងវិញ ។

ដានី៖ មូលហេតុអីបានជាគាត់លែងអី?

រៀវ៖ មូលហេតុមកពីខ្ញុំអត់មានរឿងអី ។

ដានី៖ បើ៣នាក់ទៀតគេអត់ប្រលែងទេ?

រៀវ៖ អត់ប្រលែងទេ គេយកទៅតែម្តង ។

ដានី៖ គេយកទៅសម្លាប់តែម្តង?

រៀវ៖ បាទ!

ដានី៖ យកទៅសម្លាប់នៅណា?

រៀវ៖ មានសម្លាប់នៅណាគេយកទៅសម្លាប់នៅកិលេសយើងនេះ ។

ដានី៖ កិលេសនៅណា?

រៀវ៖ នៅកន្លែងកូនក្មេងរៀនរាល់ថ្ងៃនេះ សាលាអនុវិទ្យាល័យនេះ ។

ដានី៖ សាលាអនុវិទ្យាល័យ?

រៀវ៖ បាទ!

ដានី៖ វិទ្យាល័យថ្មពួកហ្នឹង?

រៀវ៖ បាទ! ផាប់នៅកន្លែងនោះឯង ហើយខ្ញុំរត់ទៅស្រុកថ្ងៃរួចបានពួកឈ្លបឈ្មោះអាទឹម អាទុត នោះថាឲ្យម្តាយខ្ញុំឲ្យខ្ញុំទៅប្រជុំនៅសាលាកិលេស ប៉ុន្តែខ្ញុំរត់ផុត ។

ដានី៖ ចុះអ៊ំបន្ទាប់ពីប្រធានសន្តាត់ដោះលែងអ៊ំមកវិញហ្នឹងគេឲ្យអ៊ំធ្វើប្រធានអីគេ?

រៀវ៖ ខ្ញុំធ្វើខាងឈ្លប ។

ដានី៖ អ៊ំធ្វើខាងឈ្លប?

រៀវ៖ បាទ! ហើយឈ្លបហ្នឹងអញ្ចេះទៀត ឈ្លបវាមានសាខាវា ដូចថាសាខាធ្វើឈ្លបមិនបានការហ្នឹង ក៏គេហៅថាសាខាក៏ជាអ្នកធ្វើ ហើយយើងម៉េចដឹងថាវាមិនបានការយ៉ាងណា ហើយគេបន្ទោស ខ្ញុំថាធ្វើឈ្លបមិនដែលបានមនុស្សនឹងគេមួយ ហើយខ្ញុំថាវ៉ៃម៉េចបើគ្មានមនុស្សខុសផងឲ្យវ៉ៃយ៉ាង ម៉េច គេថាយើងមិនដែលបានមនុស្សវ៉ៃនឹងគេមួយ ថ្ងៃណានេះវ៉ៃឲ្យបានហ្នឹងគេមួយទៅខ្លួនឯង ហ្នឹង ហើយខ្ញុំថាទេខ្លួនឯងឬមិនខ្លួនឯងវាមិនអីទេ តែសំខាន់វាអត់មានមនុស្សខុស ហើយខ្ញុំខាង ផ្នែកសេដ្ឋកិច្ចហ្នឹងបានចូលលោតបន្តិចដែរ ប៉ុន្តែបើមានអ្នកណាសុំអង្ករយកទៅស៊ីយកអីហ្នឹង យកទៅ ដល់យកទៅគេកសាងខ្ញុំ ខាងផ្នែកនារតីគេកសាងខ្ញុំសព្វគ្រប់ ។

ដានី៖ អឹងអញ្ចឹងគេឲ្យអ៊ំធ្វើឈ្លប មូលហេតុអីបានជាគេឲ្យអ៊ំធ្វើឈ្លប?

វៀវ៖ មូលហេតុមិនដឹងជាគេគិតយ៉ាងម៉េចទេ ប្រហែលជាគេគិតថាមានគោលដំហរល្អឬក៏មានសេចក្ដីស្មោះត្រង់ក៏មិនដឹង ព្រោះយើងមិនដឹងដែរណា៎ ។

ដានី៖ ឈ្លបហ្នឹងឈ្លបយ៉ាងម៉េច?

វៀវ៖ ឈ្លបសង្កាត់ថ្មពួកហ្នឹង ហើយមើលទាំងអស់ទាំងទូទៅ ហើយខ្ញុំមិនដែលទៅចាក់ចុចអ្នកណាទេ អ្នកណាមានរាយការណ៍ធ្វើពីគេធ្វើឲ្យគេខូចធ្វើទៅ ខ្ញុំមិនចេះធ្វើទេ ។

ដានី៖ ឈ្លបសង្កាត់ថ្មពួកដល់ពេលអញ្ចឹងគេមានណែនាំឲ្យយើងធ្វើអីខ្លះ?

វៀវ៖ គេណែនាំឲ្យយើងទៅយកការណ៍ ស៊ើបអង្កេតមើលមានខ្មាំងចូលពីខាងណាមក មានខ្មាំងមានមនុស្សប្លែកពីខាងណាខ្លះ ស្រីឬក៏ប្រុសហើយអាយុប៉ុន្មាន នៅភូមិណាស្រុកណា មកពីណារត់មកពីណា នៅឯណាហើយត្រូវប្រាប់គេប្រយ័ត្នតែគេរកឃើញប្រយ័ត្នឈ្លបហ្នឹងគ្រោះថ្នាក់ ។

ដានី៖ ពីណាគេជាអ្នកប្រាប់?

វៀវ៖ ប្រធានសង្កាត់ ។

ដានី៖ ប្រធានឈ្លបឈ្មោះអី?

វៀវ៖ ប្រធានឈ្លបឈ្មោះអា ទ ។

ដានី៖ ទ ហ្នឹងមកពីណាមក?

វៀវ៖ ទ ហ្នឹងនៅភូមិយើងនេះឯង នៅភូមិថ្មពួកហ្នឹង មើលនៅភូមិមាត់ចាស់ ។

ដានី៖ នៅភូមិមាត់ចាស់?

វៀវ៖ បាទ! អា ទ ហ្នឹងខ្លាំងណាស់ ។

ដានី៖ ខ្លាំង?

វៀវ៖ ហ្នឹងអើយ ។

ដានី៖ ឈ្មោះ ទ?

វៀវ៖ ហ្នឹងអើយ ម៉េចបានវាឈ្មោះទ មកពីវាធំណាស់ កាលហ្នឹងវាសម្ងុត វាសម្ងុតខ្ញុំនៅភូមិជញ្ជាំងសម្ងុតហ្នឹងសម្ងុតរឿងអញ្ចេះទេ កាលហ្នឹងប្រធានសហករណ៍ឲ្យនៅមើលបងប្អូន ឲ្យនៅមើលបងប្អូនឈឺស្អាត់គ្រុនរងារ ពេលនោះឯងមាននារីមួយនាងកើតកូនម៉ោង១២យប់ ហើយពេលកើតកូនមកធ្លាក់តែកូនសក់នៅក្នុងពោះ ដល់ហើយគេសួរកឈ្មោះខ្ញុំថា មិត្តវៀវនៅណា ហើយសួចំខ្ញុំដែរ ហើយខ្ញុំកំពុងតែខ្លាចគេចាប់ខ្ញុំយកទៅវៃចោលផង ហើយខ្ញុំថាឆ្លើយថាមិនដឹងទេដើរសួតាមគេតាមឯងទៅ ហើយខ្ញុំម៉េចមិនសួគាត់ទៅសួរកអីគាត់ ថាកើតកូនគេពេលយប់គេចង់យក

គាត់ទៅវៃចោលណា ហើយយកយាយម៉បហ្នឹងទៅវៃចោល ហើយខ្ញុំក៏ទៅជួយទៅជួយអម អាប ខ្ញុំដឹពីបន្ទិលដល់ពេលថ្មីៗ ៗ ធ្លាក់ប៉ុននេះ?

ដានី: ធ្លាក់អីគេអាហ្នឹង?

វៀវ: ធ្លាក់សុក ធ្លាក់មកប៉ុកខៀវស្រវ៉ែ ដល់ពេលនេះទៅបានយាយម៉បគាត់អរគាត់ ហើយសួរខ្ញុំ ថាអាអូនឯងមានប្រពន្ធនូវ ហើយនៅណា ហើយខ្ញុំថាខ្ញុំនៅភូមិស្វាយ ហើយនៅថ្មពួកគាត់អរ គាត់ អរសល់សព្វថ្ងៃ ប៉ុន្តែឥលូវមិនដឹងម៉េចទេព្រោះបែកគ្នាយូហើយ ឥលូវរឿងនេះសូម ស្មេះត្រឹមហ្នឹង សូមលោកមានប្រសាសន៍មកទៀត ។

ដានី: អញ្ចឹងដល់ពេលអំផ្ទើឈ្លបហ្នឹងគេណែនាំឲ្យយើងយកការណ៍ក្រែងលោមានខ្មាំងមានអី ចុះតាម ផ្ទះតាមអីគេឲ្យយើងតាមដានអីយ៉ាងម៉េច?

វៀវ: តាមផ្ទះតាមដានដែរតែឈ្លបភូមិគេ ។

ដានី: ឈ្លបភូមិគេអ្នកតាមដាន ហើយយើងឈ្លបឃុំអត់ទេ?

វៀវ: យើងឃុំគ្រាន់តែគេបង្គាប់ថាឲ្យក្តាប់រួម ។

ដានី: ក្តាប់រួម?

វៀវ: បាទ! គ្រាន់តែប៉ុណ្ណោះឯង ។

ដានី: ចុះពេលដែលគេត្រូវចាប់មនុស្សគេឲ្យអំទៅចាប់ឬក៏យ៉ាងម៉េច?

វៀវ: អត់ទេអត់មានខាងឃុំចាប់ទេ មានតែខាងមេក្រុមមេអីគេចាប់នោះឯង មេក្រុមបាវ ជួនកាល ឈ្លបហ្នឹងឯង ហើយពួកខ្ញុំអត់មានប៉ះពាល់ទេ ។

ដានី: អត់ដែលចាប់ទេ?

វៀវ: មិនដែលចាប់ទេ ខ្ញុំមិនដែលវវល់ គេមិនឲ្យប៉ះពាល់ទេ ។

ដានី: ម៉េចអញ្ចឹង?

វៀវ: គេគ្រាន់តែឲ្យយកពត៌មានឲ្យគេប៉ុណ្ណោះ ។

ដានី: គេគ្រាន់តែឲ្យយកពត៌មានឲ្យគេ?

វៀវ: បាទ! ឲ្យរាយការណ៍ប្រាប់ទៅសហករណ៍ ហើយសហករណ៍ធ្វើការចុះមកដល់ប្រធានភូមិ ។

ដានី: ចុះមានកាំភ្លើងមានអីដែរ?

វៀវ: កាំភ្លើងអត់មានទេ ។

ដានី: ឈ្លបអត់មានកាំភ្លើងទេ?

វៀវ: អត់មានទេ អាហ្នឹងនិយាយឲ្យការពិតតែម្តង និយាយតាមត្រង់អត់មានកាំភ្លើងមានអីទេ ។

ដានី៖ គេឲ្យធ្វើការអញ្ចឹង ចុះគេមានឲ្យធ្វើស្រែធ្វើអីទេ?

វៀរ៖ ធ្វើស្រែក៏ធ្វើ ធ្វើការក៏ធ្វើដូចតែគ្នា ធ្វើជាងគេទៀតផង សកម្មជាងគេទៀតផង សកម្មជាងគេខ្លាំងណាស់អត់មានបានឈប់បានឈរអីពេលយប់ក៏អញ្ចឹង កុំតែអត់ទ្រុនទ្រាបើទ្រុនទ្រាយ៉ាប់ហើយ ។

ដានី៖ ចុះធ្វើឈ្លបបានរយៈពេលប៉ុន្មាន?

វៀរ៖ មិនដឹងបានប៉ុន្មានទេ កាលពីខ្ញុំមកពីភ្នំដញ្ឆាំងមកបានបន្តិចបន្តួចបើគិតទៅបានតែ៨ខែទេ ។

ដានី៖ បាន៨ខែផ្លាស់មកធ្វើអីវិញ?

វៀរ៖ បាន៨ខែហើយគេបញ្ចេញខ្ញុំឲ្យមកធ្វើស្រែវិញ ហើយខ្ញុំរត់ទៅស្រុកថៃ ។

ដានី៖ ចុះធ្វើសេដ្ឋកិច្ច?

វៀរ៖ ធ្វើសេដ្ឋកិច្ចធ្វើជាមួយរួមគ្នានោះអី ដែលថាធ្វើឈ្លបនោះ ។

ដានី៖ អញ្ចឹងកាលធ្វើឈ្លបហ្នឹងធ្វើសេដ្ឋកិច្ចផង?

វៀរ៖ បាទ! សេដ្ឋកិច្ចឃុំរួម ។

ដានី៖ ធ្វើសេដ្ឋកិច្ចឃុំរួមហើយនឹងធ្វើឈ្លប?

វៀរ៖ បាទ! ប៉ុន្តែខ្ញុំធ្វើប្រធានសេដ្ឋកិច្ចខ្ញុំមិនសូវបានក្តាប់អីឲ្យបានស្រួលបួលនោះទេ គ្រាន់តែជាឈ្មោះជានាមហ្នឹង ខ្ញុំមានបានទៅវើរវល់អីជាមួយហ្នឹងអ្នកណាអ្នកណីនោះ អត់មានអ្នកណាថាអញ្ចេះថាអញ្ចោះអីអត់មានទេ ។

ដានី៖ ចុះកាលជំនាន់អ៊ំធ្វើប្រធានសេដ្ឋកិច្ចអ៊ំអត់មានចាប់អីពីណាទេ?

វៀរ៖ អត់មានទេ ខ្ញុំអត់មានចាប់ពីណាសោះ តែអ្នកណាក៏អត់មានដែរ ហើយក៏រត់ទៅស្រុកថៃទៅ ។

ដានី៖ អ៊ំរត់ទៅស្រុកថៃនៅឆ្នាំណា?

វៀរ៖ ខ្ញុំរត់ទៅស្រុកថៃនៅឆ្នាំ១៩៧៨ ខែ៧ ថ្ងៃទី២២ ។

ដានី៖ ម៉េចបានជារត់ទៅស្រុកថៃ?

វៀរ៖ បើខ្ញុំមិនរត់ទេខ្ញុំនឹងត្រូវស្លាប់នៅពេលព្រឹកនោះឯង ត្រូវពួកឈ្លបគេចាប់នៅពេលព្រឹកនោះឯងព្រោះខ្ញុំជាប់ខាងស្វាយត្រាំខាងសម្តេចឪ សម្តេចព្រះនរោត្តមសីហនុ ។

ដានី៖ ជាប់ទិន្នាការ?

វៀរ៖ ជាប់ទិន្នការ ដល់មកដល់សម័យលន់ នល់ទៀតនៅស្វាយត្រាំដដែលទៀត យាមឈប់មិនបានហើយបានពួកប៉ុល ពតវាឃុំខ្ញុំសម្បើមណាស់ ។

ដានី៖ នៅហ្នឹងពួកខាងណាមកចាប់ ពួកខាងមកពី...ពូធ្វើអីបានមកចាប់ពូ?

រៀវៈ ប៉ុល ពតណាំ?

ដានីៈ បាទ!

រៀវៈ ពួកនោះខាងនារតី ទាំងប្រុសទាំងស្រីទាំងប្តីទាំងប្រពន្ធគេ ។

ដានីៈ រត់ទៅស្រុកថៃហ្នឹងគ្នាច្រើនទេ?

រៀវៈ រត់ទៅស្រុកថៃហ្នឹងគ្នា១៨នាក់ ខ្លះទៅអាមេរិច ទៅអាមេរិចប៉ុន្មាននាក់ទេ ។

ដានីៈ រត់ទៅស្រុកថៃគ្នា១៨នាក់ហ្នឹងយ៉ាងម៉េចសុទ្ធតែជាប់ទិន្នាការទាំងអស់ឬក៏ម៉េច?

រៀវៈ ខ្លះជាប់ទិន្នាការ ហើយមានតែក្មេង២នាក់ទេដែលមិនជាប់ ។

ដានីៈ ក្រៅពីហ្នឹងជាប់ទិន្នាការទាំងអស់?

រៀវៈ បាទ! ក្រៅពីហ្នឹងជាប់ទិន្នាការទាំងអស់ ។

ដានីៈ ជាប់ទិន្នាការយ៉ាងម៉េច?

រៀវៈ ជាប់ទិន្នាការដូចថាយើងធ្វើទាហានលន់ នល់ ដូចជាទាហានយើងដែលថាធ្វើស៊ុយត្រាំ ដូចជាយើងធ្វើ...តែនេះជាប់ទិន្នាការគេយកទាំងអស់ យកទាំងចាស់យកទាំងក្មេងអាណាក៏យកដែរ ។

ដានីៈ ដែលអ៊ំមានប្រសាសន៍ដំបូងថាប្រធានមួយដែលគេវៃនៅកោះហើយងើបមកវិញអត់ស្លាប់ហ្នឹងរត់ទៅជាមួយគ្នាទាំងអស់?

រៀវៈ រត់ទៅជាមួយគ្នាទាំងអស់ ។

ដានីៈ ឈ្មោះតាអីហ្នឹង?

រៀវៈ ឈ្មោះតាជៀប ។

ដានីៈ តាជៀបហ្នឹងគាត់ប្រធានអី?

រៀវៈ អនុសហករណ៍ ។

ដានីៈ អនុសហករណ៍? ក្រែងអនុសហករណ៍ឈ្មោះសាំ ហើយចុះសាំហ្នឹងគាត់មកពីណា?

រៀវៈ គាត់មកពីខាងក្រោម តែអាហ្នឹងវាជាភូមិដែរ ។

ដានីៈ គេសម្លាប់ដែរអត់ទេ?

រៀវៈ សាំហ្នឹងគេប្រធានសហករណ៍ ។

ដានីៈ អញ្ចឹងអត់អីទេ?

រៀវៈ អត់អីទេ ។

ដានីៈ គេធ្វើរហូតដល់ណា?

រៀវៈ គេធ្វើរហូតដល់ណាទេ តាំងពីខ្ញុំរត់ទៅមិនដឹងគេទៅដល់ណាទៀតទេ ។

ដានី៖ អញ្ចឹងរត់ទៅជាមួយតាជៀប?

វៀវ៖ ខ្ញុំរត់ទៅជាមួយតាជៀប តាជៀបហ្នឹងគាត់នាំខ្ញុំទៅ ។

ដានី៖ តាជៀបនៅណាឥលូវ?

វៀវ៖ តាជៀបនៅភូមិខាងកើតនោះ ។

ដានី៖ អញ្ចឹងឥលូវគាត់នៅជិតហ្នឹងដែរឬក៏អត់ទេ?

វៀវ៖ មិនដឹងជាយ៉ាងណាព្រោះមិនមែនជាបងប្អូនទំនាក់ទំនងគ្នាជាមួយគ្នាទេ ព្រោះវាជួបគ្នាកាលជំនាន់ប៉ុល ពត ឃ្លាត់គ្នាហើយដាច់តែម្តង ។

ដានី៖ ចុះពេលដែលរត់ទៅថៃយ៉ាងម៉េចទៅ១៨នាក់ហ្នឹង?

វៀវ៖ រត់ទៅថៃ១៨នាក់ហ្នឹងនៅរស់ ។

ដានី៖ រត់ទៅយ៉ាងម៉េចទៅ ហើយរត់ទៅតាមណាទៅ?

វៀវ៖ រត់ទៅតាមវាលស្រែកាត់ថ្នល់ខាងលិច កាត់ព្រៃកេសហើយឡើងទៅថ្នល់ ។

ដានី៖ ហើយកាត់ថ្នល់ហើយចូលទៅថៃកន្លែងណា?

វៀវ៖ ចូលទៅថៃកន្លែងស្រដែ ។ី

ដានី៖ ដល់ថៃ ថៃអត់មានថាអីទេ?

វៀវ៖ ថៃគេអត់មានថាអីទេ គ្រាន់តែគេថាខោអាវ ប៊ិច មានស្អីឲ្យខ្ញុំទាំងអស់មកហើយចាំមកយកវិញ អាហ្នឹងនយោបាយថៃ ដល់ឥលូវគេប្រើនយោបាយទៀតហើយ ទៅខ្ញុំដឹងហើយបើចង់យកក៏យកទៅចុះ ទុកតែខោមួយហើយអាវដៃខ្លីមួយក៏បានដែរ ដល់ហើយគេយកប៊ិចគេយកស្អីៗមានស្អីគេយកអស់ទៅ ហើយចាំមកយកវិញ ទៅយកវិញយ៉ាងម៉េចបើពួកអស់ហ្នឹងគេដាក់ខ្នោះហើយគេចេញមកវិញម៉េចរួច ហើយទៅយកធ្វើអីរបស់ប៉ុននោះហ្នឹង អាយុជីវិតប៉ុនណាណីទៅយកខោអាវប៉ុណ្ណឹងធ្វើអី ខ្ញុំមិនយកទេ អានេះស្ទេះត្រឹមនេះ ហើយមួយទៀតខ្ញុំសូមជម្រាបមួយទៀតគេដឹកពួកនោះទៅអស់ ហើយពួកខ្ញុំ៧នាក់បានគេទាហានស្រដែគេឲ្យទាហានខាងឡាក់គេមកយក គេបវឡានមកគេថាឈប់ចាំបន្តិចសិនទៅ បន្តិចទៀតឡានពួកទាហានគេមកយកហើយ ដល់នេះទៅគេបវឡានងឹងមកមានអីគេជង់ក្បាលយើងហើយឲ្យយើងឡើងឡាន គេអត់ឲ្យយើងឃើញគេចងមុខយើងណា មិនដឹងគេធ្វើលេងអីទេ គេចងមុខយើងហើយដល់ពេលទៅដល់តាមផ្លូវឆ្ងាយ ដល់ហើយអាមិត្តវាមើលទៅឃើញព្រឹមៗ គេចោលទីនេះឯងអាហ្នឹងខ្ញុំថាអញ្ចឹងណា៎ ខ្ញុំថាប្រហែលជាគេយកមកវៃចោលទីនេះឯង ដល់ហើយគេឲ្យចុះដល់ពេលឲ្យចុះទៅគេស្រាយសំពត់មុខចេញ គាត់ក៏បវឡានមកវិញទៅហើយឲ្យពួកអាខ្មែរសនោះមកនៅភ្នំឆ័ត្រ

យើង ហើយបានគេចាត់ឲ្យធ្វើខ្ទមពាន្ទង ធ្វើអីសព្វគ្រប់ រកបាយរកម្ហូបរកត្លាមអីហូបខ្លួនឯងទៅ ធ្វើម៉េចឲ្យតែបានឆ្អែតខ្លួនឯងទៅ ។

ដានី: អ្នកដែលដឹកមកចង់មុខហ្នឹងខាងទាហានថៃ?

វៀវៈ ខ្មែរសយើងចាស់ដែលគេរត់ទៅមុន ។

ដានី: អ៎! បានន័យថាដំបូងទៅដល់ថៃហ្នឹង ថៃឲ្យទៅគុកខ្មែរស?

វៀវៈ បាទ!

ដានី: ឲ្យអ៊ុំទាំង១៨នាក់ហ្នឹងទៅគុកខ្មែរស?

វៀវៈ បាទ!

ដានី: ខ្មែរសគេចង់មុខអ៊ុំហើយដឹកតាមឡានមកភ្នំឆ័ត្រ?

វៀវៈ បាទ!

ដានី: ហ្នឹងឆ្នាំណា?

វៀវៈ ឆ្នាំ១៩៧៨ ។

ដានី: ទៅភ្នំឆ័ត្រឆ្នាំ៧៨?

វៀវៈ បាទ!

ដានី: ខ្មែរសជាមួយពីណាគេខ្លះហ្នឹង?

វៀវៈ ខ្មែរសកាលនោះមានមេគេធំៗដែរ ។

ដានី: មេឈ្មោះអី?

វៀវៈ មេឈ្មោះគីម សំអ៊ុន ហៅ លួត ហៅមាំង ហៅសុកអីហ្នឹង ។

ដានី: ពួកប៉ារ៉ាកាលហ្នឹង?

វៀវៈ ប៉ារ៉ា តែដឹងម៉េចគេហៅតែខ្មែរស ដល់ហើយក្លាយមកប៉ារ៉ា ។

ដានី: អាហ្នឹងប៉ារ៉ារបស់ខាងតាសឿន សានហ្នឹង?

វៀវៈ របស់តាសឿន សាន នេះមុនដំបូងរបស់តាសឿន សាន ហ្នឹងមុនគេ ។

ដានី: អញ្ចឹងនៅភ្នំឆ័ត្រហ្នឹងតាំងពីឆ្នាំ៧៨មក ហើយយួនអត់ទាន់ចូលមកទេ?

វៀវៈ យួនអត់ទាន់ចូលមកទេ ខ្ញុំទៅនៅនោះខ្ញុំយាមនោះ ខ្ញុំដេកយាមនៅនោះ យាមស្ងួតតែអត់មានកាំភ្លើងហ្នឹង គ្រាន់តែធ្វើគោរពការកិច្ចរបស់មេខ្មែរសឲ្យបានហ្នឹងដើម្បីកុំឲ្យគេយកទៅវ៉ៃចោល ខ្ញុំតែងតែឈឺគ្រុនរង៉ារ អារឿងអត់បាយអត់ទឹកវាទ្រាំមិនសូវបាននោះ ខ្ញុំមានសេចក្តីអរគុណគេជគុណដែលបានសួនាំ តែខ្ញុំនិយាយប្រហែលជាមានការខុសឆ្គង ។

ដានី៖ ចុះបន្ទាប់មកអ៊ំនៅភ្នំឆ័ត្ររហូតដល់ពេលណាទៅ?

វៀវ៖ ភ្នំឆ័ត្រខ្ញុំអត់មានបានទៅប៉ះពាល់ហ្នឹងគេទេ អត់មានបានទៅនៅទេ អ៊ំនិយាយខុស ភ្នំឆ័ត្រនៅខាងត្បូងខ្ញុំនៅ នៅខាងត្បូងខុមខ្ញុំ ។

ដានី៖ អញ្ចឹងខ្ញុំនៅខុមនោះរហូតដល់ពេលណា?

វៀវ៖ នៅខុមនោះរហូតដល់ពេលខ្ញុំចាកចេញមកមិនដឹងជាគេដុតចោលឬក៏ម៉េច ឬមួយក៏ប្រគល់ឲ្យអ្នកណា?

ដានី៖ ឆ្នាំណាអ៊ំចាកចេញមក?

វៀវ៖ ឆ្នាំ៧៨នេះឯង ។

ដានី៖ មកណាវិញទៅ៧៧,៧៨ហ្នឹង?

វៀវ៖ គេបញ្ជូនឲ្យមកនៅក្រុងតាបផ្ទាតែម្ដង ។

ដានី៖ តាបផ្ទានៅណា?

វៀវ៖ នៅក្នុងប្រទេសថៃ ។

ដានី៖ ខេត្តណាហ្នឹង?

វៀវ៖ ខេត្តជុំបូរី ស្រុកថៃ ។

ដានី៖ ហើយម៉េចទៀតទៅនៅទីនោះ?

វៀវ៖ ហើយទៀតមកក៏គេដឹកទៅដល់តាបផ្ទាហើយបានទាហានថៃណែនាំប្រៀនប្រដៅថាឲ្យថែរក្សាខ្លួនប្រាណឲ្យបានល្អ គោរពវេលាថ្ងៃថ្នូរកុំឲ្យមានចំបងអីណា ដល់ហើយទៅបានគេយកទៅក្រោមដើមចំបក់ ដល់ពេលទៅដល់ក្រោមដើមចំបក់ហើយក៏គេឲ្យឡាមម្នាក់មួយៗដើម្បីឲ្យយើងកោសក់ដើម្បីកុំឲ្យប្រទ្បាំជាមួយប្រជាពលរដ្ឋគេ ឲ្យកោសក់ត្រងោលទាំងអស់គ្នាតែម្ដង ហើយក៏នាំគ្នាកោ ហើយដល់ពេលកោសក់អីរួចរាល់អស់ហើយអត់មានអីស៊ីទេ ជួនកាលដើរជួយលាងអីគេ គេឲ្យលុយមកបានទិញអន្ករមួយគីឡូ ហើយជួនកាលគេមិនរកអញ្ចឹងទៅក៏ទៅជួយលាងចានឲ្យគេបានគេឲ្យហូបបាយទៅ ឯងអត់មានបក្សពួក អត់មានបងប្អូន អត់មានគ្នីគ្នាគេមិនឲ្យយើងធ្វើទេ ហើយគេឲ្យយើងទៅលុះត្រាតែគេស្គាល់យើងនៅវត្តតាបផ្ទាហ្នឹងណា៎!

ដានី៖ បាទ!

វៀវ៖ ស្ដាប់ខ្ញុំឲ្យបាននៅវត្តតាបផ្ទាហ្នឹងលុះត្រាតែយើងមានបងប្អូនដឹកនាំទៅបានមានស៊ី បើស៊ីបាយនៅតាបផ្ទាបើដួសមុនគេបានច្រើន បើដួសកណ្ដាលគេឬក៏ក្រោយគេដួសទៅវាជាប់បានតែបន្តិចហើយសម្លរមានតែផ្លែត្រឡាចពីបីហ្នឹងចំណាំ ហើយដេកហៅទៅ ។

ដានី៖ ហើយម៉េចទៀតទៅ?

វៀវ៖ ហើយបន្តមកទៀតដេកយប់ព្រលប់អីគឺថាហាមផ្តាច់មិនឲ្យបញ្ឈរជន្គង់ បើឃើញដេកបញ្ឈរជន្គង់គឺជន្ទល់ហើយ ។

ដានី៖ ម៉េចអញ្ចឹង?

វៀវ៖ មិនដឹងម៉េចគេប្រើម៉េច ស្រុកគេអញ្ចឹង គេឲ្យដេកសណ្តូកហើយស្ងាត់ស្ងៀម ហើយឲ្យយកសំពត់ដាក់ទ្រូងឲ្យត្រឹមត្រូវ មានតែមួយទេដែលស្គាល់ឈ្មោះតា សំអួន តាសំអួននោះបានបុណ្យធំណាស់ ។

ដានី៖ ថៃ?

វៀវ៖ បាទ! គាត់បានបុណ្យធំមែនទែនព្រោះពេលណាដែលដេកក្នុងអគារណាមួយ ហើយគាត់ដើរមើលតែគាត់ឃើញមានអ្នកណាអត់មានសំពត់គ្រប់ទ្រូងគាត់គ្របឲ្យហើយ គាត់បានបុណ្យធំណាស់ព្រោះមនុស្សគាត់មានសិលធម៌ល្អ ខ្ញុំអត់មានអីទៀតទេសូមសួរទៀតចុះ ។

ដានី៖ ចុះនៅស្រុកថៃហ្នឹងរយៈពេលប៉ុន្មាន?

វៀវ៖ នៅស្រុកថៃមានរយៈពេលមួយឆ្នាំ ។

ដានី៖ នៅមួយឆ្នាំហើយយ៉ាងម៉េចទៀត?

វៀវ៖ នៅរយៈពេលមួយឆ្នាំតាំងពីឆ្នាំ១៩៧៩មកដល់ឆ្នាំ១៩៨១ ។

ដានី៖ ឆ្នាំ៨១?

វៀវ៖ បាទ! ពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨១ ហើយមកដល់ឆ្នាំ១៩៩១ខ្ញុំធ្វើទាហានប៉ាវ៉ាហើយ ហើយចុះទៅពោធិ៍សាត់ ។

ដានី៖ ចាប់ពីណាបានធ្វើទាហានប៉ាវ៉ា?

វៀវ៖ ចាប់ពីឆ្នាំ១៩៧៩ ។

ដានី៖ ៧៩ចូលធ្វើទាហានប៉ាវ៉ា?

វៀវ៖ បាទ! ទាំងអស់មានជិតមួយពាន់ ដែលគេហៅកងវរៈសេនាតូចលេខ២០៦ ។

ដានី៖ កងវរៈលេខ២០៦?

វៀវ៖ បាទ! ហើយក្នុងនោះខ្ញុំបាទមានភារកិច្ចដែលត្រូវធ្វើនោះគឺខាងផ្នែកភស្តុភា ។

ដានី៖ ផ្នែកភស្តុភា?

វៀវ៖ ភស្តុភាអស់រយៈពេល២ឆ្នាំ ឆ្នាំ១៩៧៩រហូតដល់ឆ្នាំ១៩៩៣ ។

ដានី៖ កាលហ្នឹងក្នុងកងពលណា?

រឿវៈ   នៅកងពល២០៤ ។

ដានីៈ   ពីណាគេប្រធានកងពល?

រឿវៈ   ប្រធានកងពលមានតែលោកអៀម សុគន្ធ ហៅលួត ហើយលោកសាច់ ណៅ ។

ដានីៈ   អញ្ចឹងមុខព្រួញរបស់អ៊ំនៅខេត្តពោធិ៍សាត់?

រឿវៈ   មុខព្រួញរបស់ខ្ញុំនៅប៉ែកខាងលិច គេខាងនេះផ្សេង ។

ដានីៈ   ចុះប្រពន្ធកូននៅណាអញ្ចឹង?

រឿវៈ   ប្រពន្ធកូននៅផ្ទះ ។

ដានីៈ   ផ្ទះនៅណា?

រឿវៈ   ផ្ទះនៅនេះឯង ។

ដានីៈ   ចុះកាលអ៊ំរត់ទៅថៃហ្នឹងអត់មានរត់ទៅជាមួយប្រពន្ធកូនទេ?

រឿវៈ   អត់ទេ ទៅតែឯង ។

ដានីៈ   កាលធ្វើប៉ារ៉ាមានមកជួបប្រពន្ធកូនទេ?

រឿវៈ   មកជួបដែរ ។

ដានីៈ   មកជួបឆ្នាំណា?

រឿវៈ   ឆ្នាំ១៩៨១ ។

ដានីៈ   ឆ្នាំ៨១?

រឿវៈ   បាទ! ខ្ញុំយកទៅទុកនៅជំរុំថ្មី ។

ដានីៈ   យកប្រពន្ធកូនទៅ?

រឿវៈ   បាទ! ហើយបានខ្ញុំចេញប្រតិបត្តិការណ៍នៅការពារតាមនៅម្តុំមួយជុំភ្នំព្រះ ហើយពោធិ៍សាត់ បាត់ដំបង អូរបែកខ្ទាំង ស៊ីងសង្កែ ។

ដានីៈ   អ៊ំមានដែលបានជួបសាក់ស៊ីសុខន ប៉ាន់ថៃអី?

រឿវៈ   ប៉ាន់ថៃ សាក់ស៊ីសុខន មិនដឹងនៅណាទេសព្វថ្ងៃ ។

ដានីៈ   ចុះកាលពីមុនអាសាជួបគាត់ទេ?

រឿវៈ   អាសាជួបគាត់ បើកាលនោះខ្ញុំទៅសុំតែឥវ៉ាន់របស់គាត់ហ្នឹង តាធឹប តាថុន តាអីនោះសុទ្ធតែពួកអ្នកកំពូល ពួកគេហ្នឹងកំពូលតែមិនដឹងទៅណាអស់ ។

ដានីៈ   អញ្ចឹងអ៊ំធ្វើប៉ារ៉ាហ្នឹងតាំងពីឆ្នាំ៧៩រហូតដល់៩៣?

រឿវៈ   បាទ! រហូតដល់៩៣ ហើយ៩៤,៩៥,៩៦នេះខ្ញុំទៅនៅភ្នំស្រុក ផ្លោះជាយដែនទៅនៅភ្នំស្រុក

ដានី: ទៅធ្វើអីនៅហ្នឹង?

វៀវៈ ធ្វើទាហានដែរ ។

ដានី: ធ្វើទាហានខាងណា?

វៀវៈ ធ្វើទាហានខាងប៉ុ៉ត ពួកវាលហ្នឹងគេលាយចូលគ្នាហើយ ។

ដានី: ដល់ពេលលាយចូលគ្នាអញ្ចឹងជាទាហានរបស់រដ្ឋាភិបាល?

វៀវៈ បាទ!

ដានី: អ៊ឹមានតួនាទីអី?

វៀវៈ ខ្ញុំនៅតែដដែល ។

ដានី: នៅដដែល?

វៀវៈ បាទ! នៅតែកងពលដដែល ។

ដានី: កងពលរបស់អីគេ?

វៀវៈ កងពលខាងគេហៅថាកងពលជួនកាលគេហៅកាត់មេអញ្ចឹង ។

ដានី: តែកងពលរបស់អង្គភាពណា?

វៀវៈ របស់អង្គភាព២៨ ។

ដានី: វរៈ២៨?

វៀវៈ វរៈសេនាធំ២៨ ។

ដានី: ប្រធានកងពល?

វៀវៈ ប្រធានកងពល ហើយសព្វថ្ងៃខ្ញុំឈប់ពីនោះមកខ្ញុំអត់មានបានធ្វើការអីទេតែខ្ញុំវាចេះ ស្រួលមិនស្រួលខ្ញុំសូមជម្រាបជូនចុះ ហើយខ្ញុំនៅភ្នំស្រុកអស់រយៈពេល៤ឆ្នាំកាន់ការនៅនោះ ហើយមានមេៗបញ្ជាការកងពលធំៗវរៈសេនាតូចធំ ដល់ហើយខ្ញុំផ្លាស់មករមាចនេះបានប៉ុន្មានខែប៉ុន្មានឆ្នាំហ្នឹងក៏គេឲ្យខ្ញុំជិះកប៉ាល់ហោះទៅចុះនៅភ្នំពេញ ចុះនៅតាំងក្រសាំង ហើយកប៉ាល់ហោះគេចុះចាក់សាំងនៅសៀមរាប ឡើងពីសៀមរាបទៅចុះនៅតាំងក្រសាំងទៀត ចុះពីតាំងក្រសាំងរួចហើយជញ្ជូនកាំភ្លើងទៅដាក់នៅកន្លែងបង្ហាត់ទាហានថ្មី នៅកន្លែងបង្ហាត់ទាហានបានមួយយប់នេះគេបើកខោអាវស្លៀកពាក់មកនៅឯកប់ស្រូវនេះ ខាងត្បូងភ្នំប្រសិទ្ធនេះ ដល់ពេលនោះបានខ្ញុំធ្វើអគារឲ្យទាហានដេកអស់៤ខ្នងធំៗ ដេកបានតែ១២ថ្ងៃបានពួកខាងរាជរដ្ឋាភិបាលយើងបានទៅរថក្រោះនោះ១២គ្រឿង ហើយរថផ្ទះដែកនោះមួយគ្រឿងទាំងអស់វា១៣គ្រឿង ហើយឃុំពួកខ្ញុំដូចគេទៅហ៊ុំអញ្ចឹងបន្ទាយមួយរយហើយគេយកសំណាញ់ទៅហ៊ុំនៅហ្នឹងដូង ។

ដានី: គេហ៊ុំធ្វើអី?

វៀវៈ គេហ៊ុំចាប់ ។

ដានី: ចាប់ពួកអ៊ីហ្នឹង?

វៀវៈ ចាប់ពួកប៉ាវ៉ាដែលទៅហ្នឹង ។

ដានី: ហើយម៉េចទៀត?

វៀវៈ បន្តមកទៀតចាប់ទៅ អានេះដល់យើងហើយណា៎ ដល់សម័យនេះហើយណា ប៉ុល ពតផុតហើយ ។

ដានី: បាទ!

វៀវៈ ឥលូវមកដល់សម័យនេះហើយ ដល់នេះខ្ញុំថាពួកទាហានទាំងអស់គ្នាកុំបាញ់ តែយើងបាញ់ស្លាប់គ្មានសល់មួយទេ កុំបាញ់ឲ្យសោះអត់បានទេ បានពួកនោះស្តាប់បញ្ជាខ្ញុំព្រោះខ្ញុំជាអ្នកដើរឃាត់វាព្រោះយើងមេគេ ខ្ញុំសូមដកខ្លួនថយចេញហើយខ្ញុំមិនធ្វើមេគេទេ ហើយគេអួទម្នាក់ហើយខ្ញុំថាកុំទម្លាក់ចោលរើសទុកទៅបើគេមិនយកឯងយកទៅផ្ទះទុកយកឲ្យប្រពន្ធឯងវិញទៅ កាំភ្លើងខ្ញីអីត្រូវសៀតនៅចង្កេះវៀងខ្លួន ហើយបើគេយកឲ្យគេទៅព្រោះកាំភ្លើងរបស់ជាតិមិនមែនរបស់យើងឯណា អាហ្នឹងខ្ញុំនិយាយខុសឬត្រូវលោក?

ដានី: បាទ!

វៀវៈ ដល់ហើយខ្ញុំឲ្យទាហានចេញក្រៅកុំឲ្យមានពុស្ធ ហើយដល់ពេលគេចូលមកដល់ថាឯណាមេ ដល់ហើយខ្ញុំថាទាហានខ្ញុំអត់មានមេទេ ទាហានទើបតែរៀបចំ ហើយគេថាកុហក ហើយខ្ញុំថាអ៊ើខ្ញុំចំណាស់ប៉ុននេះហើយខ្ញុំរកស៊ីកុហកធ្វើអី បើមនុស្សធ្វើការការពារជាតិតាំងពីឆ្នាំ១៩០០ប៉ុន្មានទេ កាលហ្នឹងដូចជាចូលឆ្នាំ១៩៧៨ ហើយចូលទៅនៅទីកន្លែងទាហានចូលរួបរួមគ្នាដើម្បីរួមជាកម្លាំង ។

ដានី: ចុះអ៊ីកាលអ៊ីចូលធ្វើប៉ាវ៉ាមានជួបខាងទាហានយួន ខាងរដ្ឋាភិបាល ខាងខ្មែរក្រហមអីទេហើយមានដែលវ៉ៃគ្នាដែរអត់?

វៀវៈ បាញ់គ្នា វ៉ៃគ្នាខ្លាំងណាស់ ។

ដានី: វ៉ៃគ្នាម៉េចទៅ?

វៀវៈ បើវ៉ៃយកខ្លាំងមែនទែននៅខាងលិចស្វាយចេក នៅខាងលិចអន្លង់វត់ អានោះញ៉ែកទៅដូចយើងដាក់តំរៀបសាលាអញ្ចឹង សឹងតែមិនហ៊ានមើលផង ស្ទើរតែបាយមិនបានផង គ្រាន់តែសែងមួយថ្ងៃហើយមិនចង់អស់ទៀត ហើយស្លាប់សួទៀតមិនធម្មតាទេ ។

ដានីៈ   វើខ្លាំងដែរ?

វៀវៈ   ខ្លាំងណាស់ ខ្លាំងមែនទែន ។

ដានីៈ   ចុះអ៊ីឈប់ធ្វើកងទ័ពតាំងពីឆ្នាំណា?

វៀវៈ   ឈប់ឆ្នាំ១៩៩៧ ។

ដានីៈ   ឆ្នាំ៩៧ឈប់ហើយ?

វៀវៈ   ឈប់ ។

ដានីៈ   ឈប់លែងមានឈ្មោះក្នុងកងទ័ពទៀតហើយ?

វៀវៈ   លែងមានក្នុងជួរកងទ័ពទៀតហើយ មានតែក្នុងជួរស្រែតែម្តង ។

ដានីៈ   មកនៅក្នុងស្រុកភូមិវិញ?

វៀវៈ   មកនៅក្នុងស្រុកភូមិវិញ ។

ដានីៈ   កាលហ្នឹងអ៊ីបានស័ក្តប៉ុន្មានកាលចូលធ្វើទ័ព?

វៀវៈ   កាលមុនដំបូងដែលខ្ញុំបានចូលធ្វើកាលហ្នឹងវរល់មែនទែនអាហ្នឹងគេដាក់ឲ្យត្រឹម៥ ។

ដានីៈ   ដាក់៥?

វៀវៈ   បាទ! ហើយបន្ទាប់មកទៀតសម្រិតសម្រាំងយកមែនទែនមានស័ក្តមានអីពាក់ត្រឹមត្រូវបាន២ ។

ដានីៈ   ស័ក្ត២?

វៀវៈ   បាទ! នៅផ្ទះសព្វថ្ងៃអត់មានទៅណាទេ ស័ក្ត២នៅហ្នឹង អត់មានឲ្យក្រឡេចក្រឡុចទៅណាទេ ហើយមានវិន័យជំហត្រឹមត្រូវល្អណាស់គេឲ្យយើងហើយ អានេះខ្ញុំបាទសូមជម្រាបជូន ។

ដានីៈ   ចុះអ៊ីមកដល់សព្វថ្ងៃនេះអ៊ីមានដែលបានព្ត័មានទាក់ទងនឹងតុលាការដែលគេកាត់ទោសមេដឹកនាំខ្មែរក្រហមឌុចទេ?

វៀវៈ   ខ្មែរក្រហមហ្នឹង?

ដានីៈ   បាទ!

វៀវៈ   ខ្មែរក្រហមខ្ញុំថីមិនស្តាប់ ខ្ញុំស្តាប់រាល់តែថ្ងៃ ។

ដានីៈ   អ៊ីដឹងគេកាត់ទោសឌុចមេគុកទួលស្លែងដែរឬអត់?

វៀវៈ   ខាងមេគុកទួលស្លែងនោះខ្ញុំជួនកាលស្តាប់បានតិច មិនបានស្តាប់ឲ្យបានជ្រៅជ្រះប៉ុន្មាននោះទេ សូម្បីតែឈ្មោះមេគុកទួលស្លែងនោះមិនចាំផង អានេះខ្ញុំបាទសូមអភ័យទោសបាទ ។

ដានីៈ   ហើយអ៊ីយល់ឃើញយ៉ាងម៉េចដែរតុលាកាគេកាត់ទោសរាល់ថ្ងៃហ្នឹង?

វៀវៈ   ខ្ញុំយល់ឃើញថាពួកនោះ បើខ្ញុំគិតទៅគួតែកាត់អញ្ចឹងហើយខ្ញុំពេញចិត្តគួតែកាត់ ។

ដានី៖ អ៊ំពេញចិត្ត?

វៀវ៖ ខ្ញុំពេញចិត្តព្រោះមនុស្សវើមនុស្សគ្មានពិចារណារកហេតុផល គ្មានយុត្តិធម៌ ធ្វើអីធ្វើអីតាមតែអំពើរចិត្ត សម្លាប់មនុស្សតាមតែសេចក្តីបំណងដែលខ្លួនពេញចិត្តសម្លាប់ គ្មានគិតពិចារណារកយុត្តិធម៌ មានតែអយុត្តិធម៌ព្រោះមនុស្សរស់នៅក្នុងសង្គមតែងតែមានធម៌ហើយនឹងអា តែងតែក្តីករុណាមេត្តា ធម៌ទាំងបួនដែលធ្វើឲ្យមនុស្សរស់មានជីវិតគឺអាស្រ័យដោយចេះយោគយល់គ្នា ចុះបើប៉ុល ពតវាចេះតែមាំង១អាណារស់បាន អាហ្នឹងខ្ញុំបាទសូមបញ្ចប់ត្រឹមនេះ ។

ដានី៖ ចុះតុលាការឥលូវគេកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមហើយហ្នឹងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិកើតឡើងកាលពីសម័យ៣ឆ្នាំហ្នឹងណាអ៊ំ?

វៀវ៖ បាទ!

ដានី៖ អញ្ចឹងឥលូវជនជាប់ចោទនៅក្នុងហ្នឹងមាន៥នាក់ មានអៀង សារី មាននួន ជា, មានខៀវសំផន, មានប្រពន្ធរបស់អៀង សារី ហើយនឹងឌុចទាំងអស់មាន៥នាក់ហើយគេកំពុងតែដំណើរការកាត់ទោសពួកគាត់ តែក្រោយៗនេះខាងតុលាការគេចង់កាត់ទោសបន្ថែមទៀតណា ហើយអ៊ំយល់ថាគេកាត់ទោសបន្ថែមទៀតហ្នឹងត្រឹមត្រូវឬអត់?

វៀវ៖ ខ្ញុំពេញចិត្តណាស់ ។

ដានី៖ អ៊ំពេញចិត្ត?

វៀវ៖ បាទ! ខ្ញុំមិនមានការសោកស្តាយឬក៏ថាកាត់ទោសមិនសមហេតុផលនោះទេ បើគិតទៅសមហេតុសមផលមែនទែន ម៉េចក៏ថាអញ្ចឹងបើថាខុសក៏ខុសតែខ្ញុំទៅចុះព្រោះថាវាអយុត្តិធម៌ហួសហេតុពេក ទៅស្លាប់នៅណា ដូចថាយើងចិញ្ចឹមមាន់ហើយវាស្លាប់យើងស៊ីព្រោះមនុស្សរស់នៅត្រូវមានព្រហ្មវិហារធម៌៤ហើយ យោគយល់គ្នា បើចំពោះសត្វបើចិញ្ចឹមបានវើស៊ីខ្លួនឯងទៅតែបើមនុស្សវាមានក្របខ័ណ្ឌអន្តរជាតិត្រូវត្រួតត្រាធ្វើអីធ្វើទៅចុះតែឲ្យសមរម្យណ៎ ។

ដានី៖ បាទ!

វៀវ៖ បើខ្ញុំនិយាយខុសត្រូវសូមអភ័យទោសណាលោក ។

ដានី៖ អត់អីទេអ៊ំនិយាយត្រូវ ខ្ញុំសូមអរគុណអ៊ំច្រើនខ្ញុំដូចជាអស់សំនួរអីត្រូវសួរអ៊ំទៀតហើយ អ៊ំមានអីចង់បន្ថែមទេ?

វៀវ៖ ខ្ញុំសូមនាទីចុងបញ្ចប់ចុងក្រោយនេះ ខ្ញុំបាទសូមឲ្យលោកធ្វើការងារបានជួបប្រទះតែសេចក្តីសុខសេចក្តីចម្រើន ហើយជួយមើលខ្ញុំបានដែលជាមនុស្សចាស់អាយុ៦៨ឆ្នាំនេះផង ទោះបីជានៅ

ទីណាកន្លែងណាក៏ដោយខ្ញុំក៏រលឹកដល់គេជគុណដែលបានសំណេះសំណាលថ្ងៃនេះសួនាំរកហេតុផល សួរសេចក្តីកាលពីសម័យមុននឹងសម័យនេះ ខ្ញុំមានសេចក្តីត្រេកអរ គន្លឹះសំខាន់បំផុត ហើយម្យ៉ាងវិញទៀតក៏សូមឲ្យគុណព្រះរតនៈត្រ័យព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ហើយនឹងគុណព្រះមាតាបិតារបស់លោកដែលបានចូលធ្វើការបម្រើជាតិដ៏ល្អប្រពៃក្នុងលក្ខណៈមានសណ្តានចិត្តក៏សូមឲ្យទេវតាបីបាច់ថែរក្សាឃុំគ្រងលោកឲ្យបានសមប្រកបដួបប្រទះឲ្យកាន់តែឡើងបុណ្យស័ក្តថែមទៀតកុំបីឃ្លាងឃ្លាតឡើយ សូមអរគុណ ។

ដានី៖ បាទអរគុណអ៊ំ ។

«ចប់»